**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែឧសភា ឆ្នាំ២០១៧

*នៅក្នុងខែឧសភា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន:**

*-អញ្ជើញចូលរួមព្រះរាជពិធីចម្រើនព្រះជន្មគម្រប់៦៤ យាងចូល៦៥ព្រះវស្សា ថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង*

*-អញ្ជើញចូលរួមក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែ ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង*

*-អនុញ្ញាតឲ្យឯកឧត្តម* Naveen Sirvastava *ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលាក្នុងឱកាសដែលឯកឧត្តមនឹងត្រូវបញ្ចប់បេសកកម្មការទូតនៅកម្ពុជា*

*-អនុញ្ញាតឲ្យឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ទើបតែងតាំងថ្មីចំនួន០៦រូប ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍មុនពេលអញ្ជើញចេញទៅបំពេញបេសកកម្មការទូត*

*-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងស្រង់សុគន្ធវារីនៅវត្តវាលស្បូវ ក្នុងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ*

*-អញ្ជើញចូលរួមក្នុងអង្គមិទ្ទិញអបអរសាទរខួបលើកទី១៩៤ ទិវាពិភពលោកកាក*



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

បាទក្រហមអឌ្ឍចន្ទក្រហម ៨ ឧសភា ២០១៧ ក្រោមអធិបតី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញនាំយកទេយ្យវត្ថុ និងគ្រឿងបរិក្ខាថ្វាយសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយក** នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបទុមវតី នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល និងពិសារបាយសាមគ្គីជាមួយកម្មករ កម្មការិនី **នៃរោងចក្រផលិតស្ករស ក្រុមហ៊ុនភ្នំពេញ ស៊ូហ្គើរ** របស់ឯកឧត្តម **លី យ៉ុងផាត់** និងលោកគ្រូ អ្នកគ្រូ ក្រុមប្រឹក្សាឃុំ ប្រជាពលរដ្ឋ ព្រមទាំងសិស្សានុសិស្សសរុបចំនួន៦១៩០នាក់ នៅភូមិផ្តោច ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

-អញ្ជើញជួបសំណេះសំណាល និងពិសារអាហារជាមួយថ្នាក់ដឹកនាំភូមិ ឃុំ និងប្រជាពលរដ្ឋមកពី២៨ភូមិ នៃឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋមកពី០៩ភូមិ ក្នុងសង្កាត់មនោរម្យ ខណ្ឌ៧មករា និងសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាទៅគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខក្រុមគ្រួសារសព **ឯកឧត្តម មាស ក្រូច** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអតីតអនុរដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូ ចូលរួមគោរពវិញ្ញាណក្ខន្ធសពកងកម្លាំងរក្សាសន្តិសុខរបស់កម្ពុជា ក្រោមទង់អង្គការសហប្រជាជាតិចំនួន០៤រូប នៅវត្តក្រាំងធ្នង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២២២ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០៦ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចុះពិនិត្យការដ្ឋានសាងសង់អគារសិក្សាចំនួន០១ខ្នង មាន០៥បន្ទប់ ដែលជាអំណោយរបស់សមាជិក សមាជិកាព្រឹទ្ធសភា មណ្ឌលភូមិភាគទី៣ ខេត្តកណ្ដាល ស្ថិតនៅក្នុងឃុំព្រះពុទ្ធ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

-អញ្ជើញចូលរួមអបអរសាទរខួបលើកទី១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ក្រោមប្រធានបទ កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា

-អញ្ជើញពិនិត្យការដ្ឋានសាងសង់សាលាឆាន់ នៅវត្តអូរសោម ដែលជាអំណោយ របស់ ឯកឧត្តម និងក្រុមគ្រួសារ ស្ថិតនៅក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយក្រុមប្រឹក្សាឃុំ ចំនួនសរុប ៥៨២នាក់ ទូទាំងស្រុកចំនួនបីគឺ ស្រុកខ្សាច់កណ្ដាល ស្រុកមុខកំពូល និងស្រុកល្វាឯម ខេត្តកណ្ដាល

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយអាជ្ញាធរមូលដ្ឋាន ឃុំអូរ សោម ព្រមទាំងឧបត្ថម្ភថវិកាចំនួន៦,០០០,០០០រៀល សម្រាប់ជួសជុលផ្លូវលំ១ខ្សែ ដើម្បីប្រើប្រាស់ក្នុងឃុំ ស្ថិតនៅក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៣ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន១២ច្បាប់ ។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :

ក្នុងខែឧសភានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាង ក្រោម:

### ២.១.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញចុះបេសកកម្មសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានទាក់ទងនឹងបញ្ហាប្រឈម និងសំណូមពរមួយចំនួន ជាមួយនឹងប្រធានក្រុមប្រឹក្សាក្រុង ស្រុក អភិបាលក្រុង ស្រុក និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកំពង់ធំ និងខេត្តព្រះវិហារ

-អញ្ជើញចុះឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការផ្ដល់សេវាសាធារណៈនៅមូលដ្ឋាន និងរិះរកដំណោះស្រាយការប្រឈមរបស់ក្រុម

ប្រឹក្សាឃុំ ស្មៀន មេប៉ុស្តិ៍រដ្ឋបាល និងការផ្តល់ព័ត៌មានស្តីពី នីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ នៅសាលាឃុំព្រៃកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ព្រមទាំងឃុំសំបួរ ស្រុកស្វាយទាប និងសាលាឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

-អញ្ជើញចុះតាមដានឈ្វេងយល់ ប្រមូលព័ត៌មាន នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ។

**២.២.មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៥ករណី និងកំពុងពិនិត្យសិក្សាចំនួន០១ករណី

-អញ្ជើញចូលរួមប្រជុំ ដើម្បីពិនិត្យពិភាក្សាកំណត់អំពីគ្រឿងឥស្សរិយយសដែលត្រូវផ្តល់ជូនសមាជិកព្រឹទ្ធសភា សម្រាប់ចុងនីតិកាលទី៣

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមការងាររៀបចំសេចក្តីព្រាងក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីបន្តពិនិត្យ និងពិភាក្សាអំពីផែនការការងារសម្រាប់អនុវត្តបន្ត

-អញ្ជើញចូលរួមសន្និបាតបូកសរុបក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ របស់ខេត្តកោះកុង នៅសាលមហោស្រពសាលាខេត្តកោះកុង

-អញ្ជើញបើកកិច្ចប្រជុំក្រុមការងារកសិកម្ម កសិឧស្សាហកម្ម ផ្នែកឯកជន ដោយផ្តោតសំខាន់លើការនាំជ្រូករស់ពីប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាកសិករចិញ្ចឹមជ្រូក

-អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម ***វេង សាខុន*** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរកដំណោះស្រាយជូនប្រជាកសិករចិញ្ចឹមជ្រូកដែលកំពុងជួបបញ្ហាលើតម្លៃជ្រូកធ្លាក់ចុះ

-អញ្ជើញចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលាស្តីពី មេរៀនជីវិតសម្រាប់យុវជនលើកទី១០ ក្រោមប្រធានបទ គុណប្រយោជន៍នៃការសិក្សា

-អញ្ជើញចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន២៦គ្រួសារ រួមជាមួយក្រុមប្រឹក្សាសង្កាត់ជ្រោយចង្វារ និងតំណាងអង្គការមូលនិធិអភិវឌ្ឍន៍សហគមន៍ រស់នៅក្នុងសហគមន៍កុឡាឡោម២ ស្ថិតនៅភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ

រាជធានីភ្នំពេញ ។ ក្នុងនោះដែរបាននាំយកថវិកាមូលនិធិរបស់អង្គការ SELAVIP ចំនួន ២,០០០,០០០រៀល ផ្តល់ជូនលោក **ស្មាន មីន** អាយុ៩១ឆ្នាំ សម្រាប់ជួសជុលផ្ទះដែលទ្រុឌទ្រោម និងបានឧបត្ថម្ភក្រមាម្នាក់មួយជូនប្រជាពលរដ្ឋដែលបានអញ្ជើញចូលរួម

-អញ្ជើញសួរសុខទុក្ខ លោកសាស្ត្រាចារ្យ **ឃឹម អ៊ី** ទីប្រឹក្សា APF អមរដ្ឋសភា ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្រ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន៣២៧លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះ ពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៧៣លើក ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**តេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ